# រក្សាការធានារ៉ាប់រងរបស់អ្នក និងគ្រួសាររបស់អ្នក។



Medi-Cal

## ត្រូវធានាថា ព័ត៌មានរបស់អ្នកបានធ្វើបច្ចុប្បន្នភាព។

Medi-Cal ផ្តល់ការធានារ៉ាប់រងលើសេវាកម្មថែទាំសុខភាពសំខាន់ៗ សម្រាប់អ្នក និងគ្រួសាររបស់អ្នក ដែលរួមបញ្ចូល ការជួបវេជ្ជបណ្ឌិតពិនិត្យសុខភាព ថ្នាំវេជ្ជបញ្ជា ការចាក់ថ្នាំវ៉ាក់សាំង ការថែទាំសុខភាពផ្លូវចិត្ត និងច្រើនថែមទៀត។ ដូច្នេះ ប្រសិនបើអ្នកមាន Medi-Cal ត្រូវធានាថា អ្នកបន្តឡើងវិញ នៅពេលដែលត្រូវបន្តឡើងវិញ។

### ធ្វើបច្ចុប្បន្នភាពលើព័ត៌មានទំនាក់ទំនងរបស់អ្នក

រាយការណ៍ពីការផ្លាស់ប្តូរថ្មីៗចំពោះឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ និងអ៊ីម៉ែលរបស់អ្នក ដើម្បីឲ្យខោនធីរបស់អ្នកអាចទាក់ទងទៅអ្នកបាន។

### ឆែកប្រអប់សំបុត្ររបស់អ្នក

ខោនធីនឹងផ្ញើតាមប្រៃសណីយ៍ជូនអ្នកនូវលិខិតមួយអំពីលក្ខណៈសម្បត្តិសម្រាប់ Medi-Cal របស់អ្នក។ អ្នកអាចត្រូវបំពេញទម្រង់ពាក្យបន្តឡើងវិញ។ ប្រសិនបើគេផ្ញើទម្រង់ពាក្យបន្តឡើងវិញជូនអ្នក សូមបញ្ជូនព័ត៌មានរបស់អ្នក តាមប្រៃសណីយ៍ តាមទូរស័ព្ទ ដោយផ្ទាល់ ឬអនឡាញ ដូច្នេះអ្នកមិនបាត់បង់ការធានារ៉ាប់រងរបស់អ្នកឡើយ។

### បង្កើត ឬឆែកគណនីអនឡាញរបស់អ្នក

អ្នកអាចចុះឈ្មោះទទួលដំណឹងថ្មីៗអំពីសំណុំរឿងរបស់អ្នក។ បង្កើត ឬចូលក្នុងគណនីរបស់អ្នក ដើម្បីទទួលបានដំណឹងថ្មីៗទាំងនេះ។ អ្នកអាចបញ្ជូនពាក្យបន្តឡើងវិញ ឬព័ត៌មានដែលបានស្នើសុំតាមប្រព័ន្ធអនឡាញ។

### បំពេញទម្រង់ពាក្យបន្តឡើងវិញរបស់អ្នក (ប្រសិនបើអ្នកទទួលបានទម្រង់ពាក្យនេះ)

ប្រសិនបើអ្នកបានទទួលទម្រង់ពាក្យបន្តឡើងវិញ សូមបញ្ជូនព័ត៌មានរបស់អ្នកតាមប្រៃសណីយ៍ តាមទូរស័ព្ទ ដោយផ្ទាល់ ឬអនឡាញ ដើម្បីជួយជៀសវាងភាពខ្វះចន្លោះនៃការធានារ៉ាប់រងរបស់អ្នក។

**សម្រាប់សេចក្តីលម្អិតបន្ថែម និងដើម្បីស្វែងយល់ពីរបៀបធ្វើបច្ចុប្បន្នភាពលើព័ត៌មានទំនាក់ទំនងរបស់អ្នក សូមចូលទៅ KeepMediCalCoverage.org**


Office Name
-
Physical Address Line 1
Physical Address Line 2
Phone Number
Website